**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៥៥៤ សសរ. កសក

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៤១៧/៣៨៣ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលមាត្រា១ និងមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៦/០៤៣ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៦ ស្តីពីការបង្កើតគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្ម ឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
N° 200 Preah Norodom Sangkat Tonle Basak Khan Chamkarmon B V D, Phnom Penh, Cambodia Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ១៨៧ អនក្រ.បក ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលសរសេរជាអក្សរកាត់ថា " **ក.ភ១.ផ១.កសក** " ។

**ប្រការ២._**

ក.ភ១.ផ១.កសក មានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២.លោកជំទាវ | **ចាន់ ផលលឿន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣.លោកស្រី | **កៅ សុជីវី** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធានអចិន្ត្រៃយ៍ |
| ៤.លោក | **ប្រាក់ ជាតិថូ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៥.លោក | **សួន សុធឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ | សមាជិក |
| ៦.លោក | **ហ៊ឹម អូន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ៧.លោកស្រី | **កាំង ឃីម** | អនុប្រធានរដ្ឋបាលជលផល | សមាជិកា |
| ៨.លោក | **ច័ន្ទ ប៊ុណ្ណិកា** | អនុប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ៩.លោក | **ម៉ក់ ម៉ូនី** | ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ | សមាជិក |
| ១០.លោក | **ព្រំ សុមានី** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១១.លោកស្រី | **គង់ សុធីរ៉** | ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិកា |
| ១២.លោក | **គង់ ភាព** | ប្រធាននាយកដ្ឋានកសិ-ឧស្សាហកម្ម | សមាជិក |
| ១៣.លោក | **ឃី កុសល** | អនុប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ | សមាជិក |
| ១៤.លោក | **ហុក គីមឆួន** | អនុប្រធាននាយកដ្ឋានផែនការ និងស្ថិតិ | សមាជិក |
| ១៥.លោក | **ចន់ ចណ្ណារត្ន** | ប្រធានការិយាល័យផែនការនៃនាយកដ្ឋានផែនការនិងស្ថិតិ | សមាជិក |
| ១៦.លោកស្រី | **អ៊ឹម សុខា** | អនុប្រធានការិយាល័យផែនការនៃនាយកដ្ឋានផែនការនិងស្ថិតិ | សមាជិកា |
| ១៧.កញ្ញា | **សម្បត្តិ មូរ៉ាមី** | មន្ត្រីការិយាល័យផែនការនៃនាយកដ្ឋានផែនការនិងស្ថិតិ | សមាជិកា |
| ១៨.កញ្ញា | **អ៊ុក ដាវី** | មន្ត្រីការិយាល័យផែនការនៃនាយកដ្ឋានផែនការនិងស្ថិតិ | លេខាធិការ។ |

**ប្រការ៣._**

ក.ភ១.ផ១.កសក មានភារកិច្ចដូចខាងក្រោម ៖

- សហការជាមួយឯកឧត្តមរដ្ឋលេខាធិការ ជាតំណាងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាសមាជិកគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- សម្របសម្រួល និងសហការជាមួយអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយ នៃគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ក្នុងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ និងឯកសារគតិយុត្តពាក់ព័ន្ធ
- ចូលរួមសហការ និងផ្តល់យោបល់លើឯកសារគតិយុត្តពាក់ព័ន្ធនានា ដែលអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយបានតាក់តែងរៀបចំក្នុងការងារជំរុញចលនាភូមិមួយផលិតផលមួយ
- ចូលរួមសហការអនុវត្តសកម្មភាពនានា ជាមួយអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយនៃគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- សម្របសម្រួល និងសហការជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយថ្នាក់រាជធានី ខេត្ត និងមន្ទីរខ្សែបណ្តោយរបស់សាមី អង្គភាពរាជធានី ខេត្ត ក្នុងការជំរុញចលនាភូមិមួយផលិតផលមួយ
- សម្របសម្រួល និងសហការជាមួយអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការងារជំរុញចលនាភូមិមួយផលិតផលមួយ ក្នុងដែនសមត្ថកិច្ចរបស់ក្រសួង
- រៀបចំផែនការការងារប្រចាំឆ្នាំរបស់ **ក.ភ១.ផ១.កសក** និងដាក់ជូនក្រសួង ដើម្បីពិនិត្យសម្រេច តាមដាន និងវាយតម្លៃការងារជំរុញចលនាភូមិមួយផលិតផលមួយក្នុងដែនសមត្ថកិច្ចរបស់ក្រសួង
- ធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំរបស់ **ក.ភ១.ផ១.កសក** ជូនក្រសួង និងគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលថ្នាក់ដឹកនាំក្រសួងប្រគល់ជូនក្នុងការងារជំរុញចលនាភូមិមួយផលិតផលមួយ។

**ប្រការ៤._**

អនុប្រធាន សមាជិក សមាជិកា និងលេខាធិការក្រុមការងារទាំងអស់ ត្រូវអញ្ជើញចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានដែលបានទទួលសិទ្ធិពីប្រធាន ត្រូវដឹកនាំការប្រជុំជំនួស។ ប្រធាន **ក.ភ១.ផ១.កសក** មានសិទ្ធិអញ្ជើញមន្ត្រីពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចូលរួមប្រជុំតាមការចាំបាច់។

**ប្រការ៥._**

**ក.ភ១.ផ១.កសក** ត្រូវធ្វើការប្រជុំយ៉ាងតិច៣ (បី) ដងក្នុងមួយឆ្នាំ។ ក្នុងករណីចាំបាច់ **ក.ភ១.ផ១.កសក** អាចរៀបចំប្រជុំវិសាមញ្ញបាន តាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៦._**

**ក.ភ១.ផ១.កសក** មានសិទ្ធិប្រើត្រារបស់ក្រសួងក្នុងកិច្ចដំណើរការរបស់ខ្លួន។

**ប្រការ៧._**

ត្រូវបាននិរាករណ៍សេចក្តីសម្រេចលេខ១៦៥ សសរ.កសក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ ស្តីពីការបង្កើតក្រុមការងារជំរុញចលនាភូមិមួយផលិតផលមួយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**ប្រការ៨._**

អគ្គលេខាធិការ អគ្គាធិការ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៦កើត ខែមិគសិរ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល ៖**

-អគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយ

-ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ដូចប្រការ៨

-ឯកសារ កាលប្បវត្តិ